# របាយការណ៍ប្រចាំខែមិថុនា ឆ្នាំ ២០១៦ របស់មន្ទីរអភិវឌ្ឍន៍ជនបទ ខេត្តឧត្តរមានជ័យ

**១. សេចក្តីផ្តើម**

ខេត្តឧត្តរមានជ័យស្ថិតនៅទិសឧត្តរនៃព្រះរាជាណាចក្រកម្ពុជា មានចម្ងាយប្រមាណជា ៤៤១ គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ មានផ្ទៃដីសរុបចំនួន ៦.៦៣១,៧២ គីឡូម៉ែត្រក្រឡា។ ខេត្តនេះមានព្រំប្រទល់ខាងកើតជាប់នឹងខេត្តព្រះវិហារ ខាងលិចជាប់នឹងខេត្តបន្ទាយមានជ័យ ខាងត្បូងជាប់នឹងខេត្តសៀមរាប និងខាងជើងប្រវែង ២២៥ គីឡូម៉ែត្រជាប់នឹងខេត្តស៊ីសាកេត ខេត្តបុរីរ៉ុំ និងខេត្តសុរិន្ទ្រ ប្រទេសថៃ និងមានស្រុកចំនួន ០៤ និងក្រុង ១ គឺស្រុកអន្លង់វែង ស្រុកត្រពាំងប្រាសាទ ស្រុកចុងកាល់ ស្រុកបន្ទាយអំពិល និងក្រុងសំរោង។

**២. ស្ថានភាពរបស់មន្ទីរ**

**២.១ ការងាររដ្ឋបាល និងបុគ្គលិក**

មន្ទីរអភិវឌ្ឍន៍ជនបទខេត្តឧត្តរមានជ័យ ដឹកនាំដោយប្រធានមន្ទីរ ០១ រូប និងអមដោយអនុប្រធានមន្ទីរចំនួន ០២ រូប រួមមាន បុគ្គលិកសរុបចំនួន ៣៣ នាក់ ក្នុងនោះនៅកម្រិតរដ្ឋបាលថ្នាក់មន្ទីរមានការិយាល័យជំនាញចំនួន ០៨ និងថ្នាក់ស្រុក ០៥ ។

**២.២ កិច្ចប្រជុំផ្សេងៗ និងទំនាក់ទំនងសាធារណៈ**

- ថ្ងៃទី ២៦ ខែឧសភា ថ្នាក់ដឹកនាំមន្ទីរ និងមន្ត្រីការិយាល័យរដ្ឋបាល ០១ រូប ចូលរួមសិក្ខាសាលាស្តីពី ការពង្រឹងការអភិវឌ្ឍន៍ធនធានមនុស្ស ក្រោមអធិបតីភាព ឯកឧត្តម **សាន វិសាល** អនុរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ
- ថ្ងៃទី ០៦ ខែមិថុនា លោកប្រធានមន្ទីរចូលរួមប្រជុំគណៈអភិបាលខេត្ត ដើម្បីវាយតម្លៃស្នើសុំតែងតាំងមន្ត្រីរាជការរបស់មន្ទីរអភិវឌ្ឍន៍ជនបទ ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលខេត្ត នៅសាលាខេត្ត
- ថ្ងៃទី ០៨ ខែមិថុនា ថ្នាក់ដឹកនាំមន្ទីរ ចូលរួមប្រជុំ Pro TWG-H ប្រចាំខែឧសភា ឆ្នាំ ២០១៦ នៅមន្ទីរសុខាភិបាល
- ថ្ងៃទី ០៨-០៩ ខែមិថុនា លោកប្រធានមន្ទីរ លោកអនុប្រធានមន្ទីរ និងមន្ត្រីការិយាល័យគណនេយ្យ ០២ រូប ចូលរួមសិក្ខាសាលាពិគ្រោះយោបល់លើលទ្ធផលនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកា ២០១៧-២០១៩ និងការរៀបចំផែនការថវិកាឆ្នាំ ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសណ្ឋាគារ ខេមរា ខេត្តបាត់ដំបង
- ថ្ងៃទី ០៩ ខែមិថុនា មន្ត្រីការិយាល័យរដ្ឋបាល ០២ រូប ចូលរួមសិក្ខាសាលាចែករំលែកចំណេះដឹងស្តីពីការអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ

- ថ្ងៃទី ១២ ខែមិថុនា មន្ត្រីការិយាល័យរដ្ឋបាល ០១ រូប ចូលរួមប្រជុំពិភាក្សាលើការងារកិច្ចសហប្រតិបត្តិការរវាងប្រទេសកម្ពុជា និងប្រទេសថៃ ក្រោមអធិបតីភាព ឯកឧត្តម **ស ថាវី** អភិបាលខេត្ត នៅច្រកជប់គរគី
- ថ្ងៃទី ១៣ ខែមិថុនា លោកប្រធានមន្ទីរ ចូលរួមប្រជុំសាមញ្ញលើកទី ២៥ របស់ក្រុមប្រឹក្សាខេត្ត អាណត្តិទី ២ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ធិន** ប្រធានក្រុមប្រឹក្សាខេត្ត និងឯកឧត្តម **ស ថាវី** អភិបាលខេត្ត នៅសាលាខេត្តឧត្តរមានជ័យ
- ថ្ងៃទី ១៥ ខែមិថុនា លោកប្រធានមន្ទីរ ចូលរួមប្រជុំតាមដានភាពរីកចម្រើន និងសកម្មភាពច្រកទ្វារព្រំដែនអន្តរជាតិជាំ នៅស្រុកអន្លង់វែង ជាមួយអភិបាលខេត្តស៊ីសាកេត
- ថ្ងៃទី ១៨ ខែមិថុនា លោកប្រធានមន្ទីរ ចូលរួមគោរពវិញ្ញាណក្ខន្ធ័សពលោកព្រឹទ្ធាចារ្យ **សាយ ភូថង** នៅវត្តខ្លុងយៃ ខេត្តត្រាត ប្រទេសថៃ
- ថ្ងៃទី ២០ ខែមិថុនា មន្ត្រីការិយាល័យរដ្ឋបាល ០១ រូប ចូលរួមក្នុងវគ្គផ្សព្វផ្សាយអនុក្រឹត្យ ស្តីពីការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល និងការប្រើប្រាស់មន្ត្រីជាប់កិច្ចសន្យា ព្រមទាំងលិខិតបទដ្ឋានគតិយុទ្ធថ្មី នៅសាលាខេត្ត
- ថ្ងៃទី ២០-២១ ខែមិថុនា ថ្នាក់ដឹកនាំមន្ទីរ ចូលរួមវគ្គបណ្តុះបណ្តាលការងាររដ្ឋបាល និងបុគ្គលិក នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ និង
- ថ្ងៃទី ២១ ខែមិថុនា មន្ត្រីការិយាល័យគណនេយ្យ ០១ រូប ចូលរួមប្រជុំផ្សព្វផ្សាយសារាចរណែនាំលេខ ០៤ សរណន ស្តីពីការរៀបចំសេចក្តីព្រាងច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ ២០១៧ នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត។

## ៣. លទ្ធផលសម្រេចបានតាមវិស័យ

### ៣.១ ការងារផ្លូវជនបទ

- ចុះត្រួតពិនិត្យតាមដានបទដ្ឋានបច្ចេកទេសខ្សែផ្លូវកំពុងសាងសង់ នៅភូមិបាត់ថ្កៅ ឃុំចុងកាល់ ស្រុកចុងកាល់ ប្រវែង ៤.៥០០ ម៉ែត្រ
- ចុះត្រួតពិនិត្យតាមដានបទដ្ឋានបច្ចេកទេសផ្លូវជួសជុលខួបចាប់ពីភូមិគោកធ្នង់ ដល់ភូមិគោកត្រាង ឃុំជើងទៀន ស្រុកចុងកាល់ ប្រវែង ៨.០០០ ម៉ែត្រ សម្រេចលទ្ធផល ១០០% និង
- ចុះជ្រើសរើសទីតាំងស្ពាន លូ ដែលត្រូវសាងសង់ថ្មី លើផ្លូវជនបទទាំង ០៥ ស្រុក។

### ៣.២ ការងារផ្គត់ផ្គង់ទឹកស្អាត

- នៅថ្ងៃទី ២៦ -២៧ ខែមិថុនា មន្ត្រីការិយាល័យ ០២ រូប ចូលរួមដំណើរទស្សនកិច្ចសិក្សា ចែករំលែកបទពិសោធ ស្តីពីសិមិទ្ធិផលដែលបានអនុវត្តកម្មវិធីទឹកស្អាត និងអនាម័យ របស់គម្រោងអង្គការប្រា ក្នុងនោះរួមមានបទបង្ហាញ ស្តីពីបច្ចេកទេសសាងសង់ធុងចម្រោះជីវសាស្ត្រ បច្ចេកទេសសាងសង់បង្គន់អនាម័យ និងអាងត្រងទឹកភ្លៀង នៅភូមិពោធិ៍ថ្មី ឃុំបេងនិង ភូមិសឹង្ហ ឃុំគោកមន

ស្រុកបន្ទាយអំពិល មានសមាសភាពចូលរួមសរុបចំនួន ១៧៥ នាក់ ស្រី ៥៤ នាក់

- ថ្ងៃទី ១១-១៤ ខែមិថុនា មន្ត្រីបច្ចេកទេស បានចុះត្រួតពិនិត្យការងារសាងសង់អណ្តូងស្នប់ចំនួន ០២ អណ្តូងរួមមាន÷
  - ភូមិពុល សង្កាត់សំរោង ក្រុងសំរោង ខួងបានជំរៅ ៣៤ ម៉ែត្រ ធារទឹក ១.៥ នីវ៉ូស្តាទិច ៨ ម និងនីវ៉ូឌីណាមិច ២២ ម៉ែត្រ និង
  - ភូមិតាដេវ ឃុំត្រពាំងតាវ ស្រុកអន្លង់វែង ខួងបានជំរៅ ៥២ ម៉ែត្រ ធារទឹក ១.២ ម៉ែត្រគូប នីវ៉ូស្តាទិច ៨ ម៉ែត្រ និងនីវ៉ូឌីណាមិច ២២ ម៉ែត្រ។

## ៣.៣ ការងារថែទាំសុខភាពជនបទ

- ថ្ងៃទី ២៩ ខែឧសភា ដល់ ថ្ងៃទី ០៣ ខែមិថុនា មន្ត្រីការិយាល័យ ០១ រូប ចូលរួមមហាសន្និបាតសមាគមន៍បង្គន់អនាម័យសាធារណៈពិភពលោកលើកទី ៣ នៅសណ្ឋាគារសុខាល័យអង្គរ ខេត្តសៀមរាប រៀបចំឡើងដោយក្រសួងទេសចរណ៍។ មហាសន្និបាតនេះ ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធនានា ទូទាំង ២៥ រាជធានី-ខេត្ត និងប្រទេសជាមិត្ត សរុបចំនួន ១៧០ នាក់ ស្ត្រី ៣៧ នាក់ ក្រោមអធិបតីរបស់ ឯកឧត្តម **ប៉ាក់ សាខុន** រដ្ឋលេខាធិការក្រសួងទេសចរណ៍
- ថ្ងៃទី ០៨-១០ ខែមិថុនា ប្រជុំស្តីពីការផ្តល់ចំណេះដឹង និងការអប់រំផ្សព្វផ្សាយអនាម័យដល់សាលារៀន និងសហគមន៍ នៅឃុំពង្រ ស្ថិតក្នុងស្រុកចុងកាល់ ។ កិច្ចប្រជុំនេះរៀបចំឡើងដោយការិយាល័យថែទាំសុខភាពជនបទ នៃមន្ទីរអភិវឌ្ឍន៍ ជនបទខេត្ត រួមសហការសម្របសម្រួលជាមួយមន្ត្រីមកពីនាយកដ្ឋានថែទាំសុខភាពជនបទ នៃក្រសួងអភិវឌ្ឍន៍ជនបទ។ កម្មវិធីនេះមានការចូលរួមសរុបចំនួន ៣៥ នាក់ ស្ត្រីចំនួន ០៦ នាក់។ កលទ្ធផលសម្រេចបាននៃ កិច្ចប្រជុំរួមមាន÷
  - ស្ថានភាពទូទៅ និងអត្រាគ្រប់ដណ្តប់ទឹកស្អាត និងអនាម័យនៅក្នុងប្រទេសកម្ពុជា
  - ការប្រៀបធៀបពីអត្រាគ្រប់ដណ្តប់ទឹកស្អាត និងអនាម័យនៅតាមទីប្រជុំជន និងនៅតាមទីជនបទ
  - ការប្រៀបធៀបពីស្ថានភាពទូទៅ និងអត្រាគ្រប់ដណ្តប់ទឹកស្អាត និងអនាម័យរវាងប្រទេសកម្ពុជា ជាមួយនឹងប្រទេសក្នុងតំបន់អាស៊ាន
  - ការបង្ហាញពីផែនការយុទ្ធសាស្ត្រជាតិ ឆ្នាំ ២០១៥-២០២៥ ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យ
  - តួនាទីភារៈកិច្ចក្នុងការចូលរួមជំរុញ និងលើកកម្ពស់កម្មវិធីទឹកស្អាត និងអនាម័យដើម្បីអោយសម្រេច បាននូវភាពជោគជ័យពីសំណាក់អាជ្ញាធរមូលដ្ឋានគ្រប់ជំដាប់ថ្នាក់ និងស្ថាប័នពាក់ព័ន្ធ។

## ៣.៤ ការងារអភិវឌ្ឍន៍សហគមន៍

ថ្ងៃទី ១៣-១៧ ខែមិថុនា មន្ត្រីការិយាល័យ ០២ រូប សហការជាមួយអង្គការ FH Cambodia បាន

ចុះសហការជាមួយអាជ្ញាធរឃុំត្រពាំងប្រាសាទ ឃុំទំនប់ដាច់ ឃុំព្រះប្រឡាយ និងមេភូមិចំនួន ១៥ ភូមិ ដើម្បីជ្រើសរើសគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ រួមមាន÷ ភូមិឈូកស ភូមិអូរសោម ភូមិស្រែក្រសាំង ភូមិព្រៃស្អាត ភូមិថ្មល់កែង ភូមិដីក្រហម ភូមិតេជោអភិវឌ្ឍន៍ ភូមិទួលចារ ភូមិទួលពង្រ ភូមិទួលប្រាសាទ ភូមិចារថ្មី ភូមិជ័យនិវត្តន៍ ភូមិព្រះប្រឡាយ ភូមិអូររំដួល និងភូមិប្រាសាទក្រហមសែនជ័យ។

**៤. ទិសដៅការងារបន្ត**

- ចុះត្រួតពិនិត្យតាមដានបទដ្ឋានបច្ចេកទេសខ្សែផ្លូវជួសជុលខួប ដែលកំពុងអនុវត្ត
- ចុះត្រួតពិនិត្យ និងសិក្សាខ្សែផ្លូវជួសជុលបន្ទាន់ និងសាងសងថ្មីទូទាំងខេត្ត សម្រាប់ការអនុវត្តក្នុងឆ្នាំ ២០១៦
- ចុះប្រមូលទិន្នន័យខ្សែផ្លូវថ្មី និងធ្វើបច្ចុប្បន្នភាព សម្រាប់ឆ្នាំ ២០១៦
- សាងសង់អណ្តូងស្នប់អាហ្វ្រីដេវនៅភូមិព្រៃធំ ០១ អណ្តូង ភូមិក ០១ អណ្តូងឃុំចុងកាល់ និងភូមិសែនមនោរម្យ ១ ចំនួន ០២ អណ្តូង ឃុំគោកមន
- សាងសង់ធុងចម្រោះទឹកស្អាតចំនួន ១០០ ធុង
- ចុះអប់រំផ្សព្វផ្សាយ និងត្រួតពិនិត្យ ស្តីពីការប្រតិបត្តអនាម័យនៅតាមសហគមន៍
- សម្របសម្រួលកិច្ចប្រជុំត្រីមាសថ្នាក់ឃុំ ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យ
- សម្របសម្រួលកិច្ចប្រជុំត្រីមាសថ្នាក់ស្រុក ស្តីពីកម្មវិធីទឹកស្អាត និងអនាម័យ
- ចុះរៀបចំបញ្ចាំងវីដេអូ អប់រំអនាម័យ ពេលយប់នៅតាមសហគមន៍ និង
- រៀបចំកម្មវិធីអប់រំផ្សព្វផ្សាយ ស្តីពីអនាម័យ តាមរយៈវិទ្យុខេត្ត។